ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៥. សូមជូនៈ នាយកដ្ឋានហិរញ្ញវត្ថុ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...... សហវ.......

មកដល់ក្រសួង ស.ហ.វ

ថ្ងៃ 28 ខែ 02 ឆ្នាំ 2024

លេខចុះបញ្ជី 1125

ចូល — មកដល់ការិយាល័យ ... ហិរញ្ញវត្ថុ លេខៈ 1174

ចេញ — ថ្ងៃ....ខែ....ឆ្នាំ......ម៉ោង........

# ប្រកាស

## ស្តីពី

## ការបង្កើតក្រុមការងារតាមដាន វាយតម្លៃ និង ជំរុញការអនុវត្តនីតិវិធីអនុវត្តការងារ តាម អេហ្វអឹមអាយអេស ថ្នាក់ក្រសួង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧១៩/១០២៤ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង នៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ២៣.អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥) ២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញអនុក្រឹត្យលេខ ២៤.អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃអគ្គ-លេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញប្រកាសលេខ ៦៤៩ សហវ.ប្រក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៣៤៧ សហវ.ប្រក ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃអង្គភាពក្រោមឱវាទអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញប្រកាសលេខ ៨៥១ សហវ.ប្រក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- យោងតាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១.-**

បង្កើត "**ក្រុមការងារតាមដាន វាយតម្លៃ និង ជំរុញការអនុវត្តនីតិវិធីអនុវត្តការងារតាមអេហ្វអឹមអាយអេសទាំងស្រុង**" ហៅកាត់ថា "**ក.ត.វ.ជ.**" ។ ក្រុមការងារនេះមានភារកិច្ចក្នុងការត្រួតពិនិត្យ, តាមដាន, វាយតម្លៃ និង សិក្សាកំណត់ស្តង់ដាឯកសារ និង ថេរវេលាស្តង់ដានៃការពិនិត្យ និង អនុម័តប្រតិបត្តិការហិរញ្ញវត្ថុតាមអេហ្វអឹមអាយអេសទាំងស្រុង ដើម្បីដាក់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិនិត្យ និង សម្រេច ។

**ប្រការ ២.-**

ទិន្នន័យដែលផលិតចេញពីអេហ្វអឹមអាយអេស និង ទិន្នន័យដែលទទួលបានអំពីវិធីសាស្ត្រផ្សេងៗទៀត ដូចជាការធ្វើអង្កេតផ្ទាល់, របាយការណ៍សវនកម្មជាតិ, របាយការណ៍សវនកម្មផ្ទៃក្នុង និង អធិការកិច្ចនឹងត្រូវយកមកប្រើប្រាស់ជាមូលដ្ឋានសម្រាប់ក្រុមការងារក្នុងការតាមដាន វាយតម្លៃ និង រៀបចំស្នើឡើងជាវិធានការគន្លឹះជំរុញដល់ការអនុវត្តប្រតិបត្តិការហិរញ្ញវត្ថុឱ្យបានកាន់តែមានភាពប្រសើរឡើងរហូតដល់កម្រិតកាលបរិច្ឆេទស្តង់ដា ដែលជាកម្មវត្ថុនៃការសម្រេចចិត្តរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមលិខិតបទដ្ឋានគតិយុត្ត ។

**ប្រការ ៣.-**

ក្រុមការងារមានសិទ្ធិធ្វើលិខិតជូនដំណឹង, ជំរុញ, ក្រើនរំលឹក ឬ អញ្ជើញអគ្គនាយកដ្ឋាន ឬ បុគ្គលដែលបានរកឃើញថាបង្កនូវបញ្ហារាំងស្ទះដល់ប្រតិបត្តិការហិរញ្ញវត្ថុលើសពីកាលបរិច្ឆេទស្តង់ដាកំណត់មកធ្វើការបំភ្លឺផ្ទាល់ និង ធ្វើសេចក្តីរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីចាត់ជាវិធានការនានា រួមទាំងវិធានការទណ្ឌកម្មរដ្ឋបាលប្រសិនបើបុគ្គលនោះត្រូវបានរកឃើញថាបានប្រព្រឹត្តកំហុសមិនមានការកែប្រែបន្ទាប់ពីមានការណែនាំចំនួន ២ (ពីរ) លើករួចហើយ ។

**ប្រការ ៤.-**

ក្រុមការងារតាមដាន វាយតម្លៃ និង ជំរុញការអនុវត្តនីតិវិធីអនុវត្តការងារតាមអេហ្វអឹមអាយអេសទាំងស្រុង មានសមាសភាពដូចខាងក្រោម÷

| | | |
|---|---|---|
| ១. | ឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២. | ឯកឧត្តម **យ៉េត ធីណែល** អនុរដ្ឋលេខាធិការ និង ជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | សមាជិក |

| | | |
|---|---|---|
| ៣. ឯកឧត្តម ស៊ាន វណ្ណា | អនុរដ្ឋលេខាធិការ និង ជាប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម | សមាជិក |
| ៤. ឯកឧត្តម ជា ចុមណា | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង | សមាជិក |
| ៥. ឯកឧត្តម ឆាយ រតនៈ | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គាធិការ នៃអគ្គាធិការដ្ឋាន | សមាជិក |
| ៦. ឯកឧត្តម មន្ត ច្រាន់ថា | អគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | សមាជិក |
| ៧. លោកជំទាវ ខែត ម៉ូនីឡេន | អគ្គនាយករង នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង | សមាជិក |
| ៨. លោក ឡុញ ម៉ុណ្ណារ៉ា | អគ្គាធិការរង នៃអគ្គាធិការដ្ឋាន | សមាជិក |
| ៩. លោក ឈាង យូ | អគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | សមាជិក |
| ១០. លោក ម៉ុន ឆាយ | ប្រធាននាយកដ្ឋាន នៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | សមាជិក |
| ១១. លោក ជា តារា | ប្រធាននាយកដ្ឋាន នៃអគ្គាធិការដ្ឋាន | សមាជិក |
| ១២. លោកស្រី មោន រដ្ឋា | អនុប្រធាននាយកដ្ឋាន នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង | សមាជិក |
| ១៣. លោក ហា សុគន្ធ | ប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | សមាជិក |
| ១៤. តំណាងពីស្ថាប័ន និង អង្គភាពពាក់ព័ន្ធ ចូលរួមតាមការអញ្ជើញ ឬតាមការស្នើចាំបាច់ | | សមាជិក ។ |

**ប្រការ ៤.-**

ក្រុមការងារ មានភារកិច្ចគន្លឹះក្នុងការធានាឱ្យបាននូវនិរន្តរភាពក្នុងការអនុវត្តប្រតិបត្តិការហិរញ្ញវត្ថុតាមអេហ្វអឹមអាយអេសទាំងស្រុងចាប់ផ្ដើមតាំងពីការរៀបចំផែនការថវិការហូតដល់ការទូទាត់ជូនអ្នកទទួលផល, ការរៀបចំច្បាប់ទូទាត់ និង ការធ្វើសវនកម្ម ដែលក្នុងនោះរួមមាន ÷

- ពង្រឹងតម្លាភាព គណនេយ្យភាព និង ប្រសិទ្ធភាព នៃការអនុវត្តប្រតិបត្តិការហិរញ្ញវត្ថុតាមអេហ្វអឹមអាយអេសទាំងស្រុង
- ផ្ដល់អនុសាសន៍ជូនដល់ថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងការរៀបចំយន្តការ និង បទដ្ឋានគតិយុត្តនានា ដើម្បីធានាបាននូវប្រសិទ្ធភាព នៃការអនុវត្តប្រតិបត្តិការហិរញ្ញវត្ថុតាមអេហ្វអឹមអាយអេសទាំងស្រុង
- ផ្ដល់យោបល់លើការបង្កើតយន្តការ ឬ វិធានការដើម្បីធានាបាននូវការអនុវត្ត
- សិក្សាកំណត់យកថ្ងៃស្តង់ដាសម្រាប់កំឡុងពេលពិនិត្យ និង អនុម័តប្រតិបត្តិការហិរញ្ញវត្ថុ
- ចូលរួមពង្រឹងការអនុវត្តការបិទបញ្ជីថវិកា និង បញ្ជីគណនេយ្យរបស់រាជរដ្ឋាភិបាលស្របតាមច្បាប់ និង លិខិតបទដ្ឋានគតិយុត្តជាធរមាន
- រៀបចំជាយន្តការ វិធាន ឬឯកសារគតិយុត្តពាក់ព័ន្ធផ្សេងៗសម្រាប់ការអនុវត្តតាមស្តង់ដាជាក់លាក់ និង ការដាក់ទោសទណ្ឌសម្រាប់បុគ្គលដែលអនុវត្តខុសពីស្តង់ដាកំណត់

- ពង្រឹងការផ្សព្វផ្សាយលើប្រតិបត្តិការហិរញ្ញវត្ថុ និង ការអនុវត្តថវិកាតាមនីតិវិធីអនុវត្តការងារតាមអេហ្វអឹមអាយអេស ទាំងស្រុង
- ពង្រឹងការប្រើប្រាស់ព័ត៌មាន និង របាយការណ៍ នៃប្រតិបត្តិការហិរញ្ញវត្ថុ និង ការអនុវត្តថវិកាដែលមានស្រាប់នៅក្នុងអេហ្វអឹមអាយអេស និង ការលុបបំបាត់ការប្រើប្រាស់ ឬ ការទាមទារយកព័ត៌មាន និង របាយការណ៍ នៃប្រតិបត្តិការហិរញ្ញវត្ថុ និង ការអនុវត្តថវិកាពីបណ្ដាការដ្ឋានអេហ្វអឹមអាយអេស
- ផ្ដល់ធាតុចូលដល់ការអនុវត្តយុទ្ធសាស្ត្រគ្រប់គ្រងការផ្លាស់ប្ដូរ និង សម្របសម្រួលជាមួយអ្នកពាក់ព័ន្ធនានាក្នុងការពង្រឹងការចូលរួមប្រកបដោយបុរេសកម្មដល់ដំណើរការអនុវត្តប្រតិបត្តិការហិរញ្ញវត្ថុតាមអេហ្វអឹមអាយអេសទាំងស្រុង
- កំណត់ទិសដៅ នៃការរៀបចំផែនការរយៈពេលខ្លី, មធ្យម និង វែង ក្នុងការពង្រឹងគុណភាព, គណនេយ្យភាព, តម្លាភាព, និង ប្រសិទ្ធភាព នៃនីតិវិធីអនុវត្តការងារតាមអេហ្វអឹមអាយអេសទាំងស្រុងទាំងថវិកាចរន្ត និង វិនិយោគ ។

**ប្រការ ៦.-**

ប្រធានក្រុមការងារអាចប្រគល់សិទ្ធិជូនសមាជិកដើម្បីកោះប្រជុំ និង ដឹកនាំការងារដើម្បីសម្រេចបានតាមភារកិច្ចរបស់ក្រុមការងារ ។

**ប្រការ ៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៨.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក អគ្គនាយក អគ្គាធិការ នាយកវិទ្យាស្ថាន និង គ្រប់ប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ ៣ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃពុធ ៥កើត ខែ មាឃ ឆ្នាំ ថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែ កុម្ភៈ ឆ្នាំ ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

***កន្លែងទទួល÷***
- *ទីស្ដីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ សម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី*
- *គ្រប់ក្រសួង-ស្ថាប័ន*
- *ដូចប្រការ៨*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

លេខ ៥៥២ អយក.ចល

បានថតចម្លងត្រឹមត្រូវតាមច្បាប់ថតចម្លង

បញ្ជូនមក៖ -គ្រប់អង្គភាពនិងគ្រឹះស្ថានសិក្សាក្រោមឱវាទក្រសួង

-គ្រប់មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត

" ដើម្បីមុខការ និងជូនជ្រាប"

ថ្ងៃ សុក្រ ៦កើត ខែ ចេត្រ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០២៤

**តប.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ**

ទេព ភិយ្យោរិទ្ធ